# សុន្ទរកថា
# ឯកឧត្តម សេង សក្ដា អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ
# ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
# ថ្លែងបិទកិច្ចសន្ទនា ស្ដីពីការធ្វើសមាហរណកម្មគោលនយោបាយមុខរបរនិងការងារ
# និង កិច្ចគាំពារសង្គម

មជ្ឈមណ្ឌលសហប្រតិបត្តិការ-កម្ពុជា, ថ្ងៃទី២៨-២៩ ខែមីនា ឆ្នាំ២០១២

សូមគោរព!

- លោក Helmut Schwarzer ប្រធានទីប្រឹក្សាបច្ចេកទេសគំរោងអង្គការពលកម្មអន្តរជាតិខាងការងារ-សហគមន៍អ៊ឺរ៉ុប ប្រចាំនៅទីក្រុងហ្សឺណែវ
- លោក Vincent Vire តំណាងប្រតិភូសហគមន៍អ៊ឺរ៉ុបប្រចាំនៅកម្ពុជា
- លោក អេង កក្កដា តំណាងសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
- លោក វង្ស សុវណ្ណ តំណាងសហជីពកម្ពុជា
- ឯកឧត្ដម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ
- ភ្ញៀវជាតិ ភ្ញៀវអន្តរជាតិ ជាទីរាប់អាន !

ជាបឋម ក្នុងនាម**ឯកឧត្ដម វង សូត** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខ្ញុំមានកិត្តិយស និង មានសេចក្ដីសោមនស្សរីករាយជាអនេក ដោយបានចូលរួមជាអធិបតីក្នុងពិធីបិទកិច្ចសន្ទនាថ្នាក់ជាតិ ស្ដីពីការធ្វើសមាហរណកម្មគោលនយោបាយមុខរបរនិងការងារ និងកិច្ចគាំពារសង្គម ក្រោមកិច្ចសហការជាមួយអង្គការ ILO-EU ដែលត្រូវបានបញ្ចប់ដោយជោគជ័យនាពេលនេះ ។

ខ្ញុំសូមសំដែងសេចក្ដីអបអរសាទរ និង ស្វាគមន៍ចំពោះលទ្ធផលជាវិជ្ជមាននៃកិច្ចសន្ទនាថ្នាក់ជាតិ ស្ដីពីការធ្វើសមាហរណ កម្មគោលនយោបាយមុខរបរ និងការងារ និងកិច្ចគាំពារសង្គម ។

**ឯកឧត្ដម លោកជំទាវ លោក លោកស្រី ប្អូនៗនិស្សិត!**

ដូចដែលឯកឧត្ដម លោកជំទាវ លោក លោកស្រី បានជ្រាបហើយថា រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ជាសេនាធិការ បានរៀបចំចងក្រងឯកសារយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ និងបានប្រកាសផ្សព្វផ្សាយជាផ្លូវការ

ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពី ថ្ងៃទី ០៥-០៦ ខែធ្នូ ឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ ឯកសារនេះត្រូវបានបន្តផ្សព្វផ្សាយជាបន្តបន្ទាប់នៅគ្រប់រាជធានី-ខេត្ត។ ស្របគ្នាមួយនេះដែរ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះហត្ថលេខាត្រីភាគីលើកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា។ ចំណុច និងគោលដៅសំខាន់ៗរបស់កម្មវិធីនេះក៏ត្រូវបានបញ្ចូលទៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជាផងដែរ សំដៅធ្វើឱ្យកម្មវិធីនេះមានភាពសមស្របទៅតាមយុទ្ធសាស្ត្ររបស់ក្រសួង និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

ចំណុចខាងលើនេះ បានបញ្ជាក់យ៉ាងច្បាស់ថា យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ និង កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាបានផ្សារភ្ជាប់ និងបានធ្វើសមាហរណកម្មបញ្ចូលគ្នាជាបណ្តើរៗរួចមកហើយ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្អូនៗនិស្សិត!**

ក្នុងនាមឱ្យថ្នាក់ដឹកនាំ ខ្ញុំមានមោទនភាពជាខ្លាំងដែលអង្គការអន្តរជាតិខាងការងារ និងសហគមន៍អឺរ៉ុបបានជួយផ្តល់ជំនួយបច្ចេកទេស និងថវិកា រៀបចំឱ្យមានដំណើរការកិច្ចសន្ទនាថ្នាក់ជាតិ ស្តីពីការធ្វើសមាហរណកម្មមុខរបរ និងការងារ និងកិច្ចគាំពារសង្គម ប្រកបដោយជោគជ័យ ដែលខ្ញុំសូមចាត់ទុកថាជាការសម្រេចបានដ៏មានសារៈសំខាន់ថ្មីមួយទៀត សម្រាប់ការសម្រេចបានជាចុងក្រោយនូវគោលនយោបាយ ដែលត្រូវរៀបចំ។

ក្នុងរយៈពេលនៃកិច្ចពិគ្រោះយោបលនេះ អ្នកផ្តល់បទឧទ្ទេសនាមសុទ្ធតែអ្នកជំនាញជាន់ខ្ពស់ដែលមានបទពិសោធន៍ និង កំពុងបំពេញការងារជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអ្នកជំនាញជាន់ខ្ពស់មកពីថ្នាក់តំបន់ និងពីទីក្រុងហ្សឺណែវ ដែលកំពុងធ្វើការងារផ្ទាល់ បានជួយតម្រង់ទិសការរៀបចំបង្កើតគោលនយោបាយស្តីពីកិច្ចគាំពារសង្គម និង ការបង្កើតមុខរបរ។ ជាបន្ថែម គ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមានក្រសួងស្ថាប័នរាជរដ្ឋាភិបាល អង្គការ និយោជក អង្គការកម្មករនិយោជិត អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការជាតិ និងអង្គការអន្តរជាតិ ក៏បានចូលរួមក្នុងកិច្ចពិគ្រោះយោបល់នេះយ៉ាងសកម្ម ប្រកបដោយស្មារតីទទួលខុសត្រូវយ៉ាងខ្ពស់បំផុត ធ្វើឱ្យលទ្ធផលនៃកិច្ចពិភាក្សារបស់យើងបានកាន់តែឆ្លុះបញ្ចាំង និង ឆ្លើយតបយ៉ាងត្រឹមត្រូវទៅនឹងស្ថានភាពជាក់ស្តែងនៃកម្ពុជា ដែលជាចំណុចមួយអាចឱ្យធ្វើការវាយតម្លៃបានថា គោលនយោបាយរបស់យើងដែលនឹងត្រូវសម្រេចបាន នឹងពិតជាត្រឹមត្រូវដែលអាចអនុវត្តបានដោយជោគជ័យ ជាមិនខាន។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមឱ្យថ្នាក់ដឹកនាំក្រសួង ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ ILO និង សហគមន៍អឺរ៉ុប ដែលបានផ្តល់ជំនួយជាបច្ចេកទេស និងថវិកា ក្នុងការរៀបចំឯកសារទាំង៣ គឺ ១-**ឯកសារស្តីពី "កម្ពុជាៈ ឆ្ពោះទៅកាន់យុទ្ធសាស្ត្រជាតិ ស្តីពីមុខរបរ និងការងារដើម្បីកាត់បន្ថយ ភាពក្រីក្រប្រកបដោយចីរភាព "** ២-**៣ជ្រៀងឯកសារ ស្តីពីការត្រួតពិនិត្យឡើងវិញលើការចំណាយផ្នែកកិច្ចគាំពារសង្គម និង** ៣-**សេចក្តីព្រាងឯកសារស្តីពី កម្ពុជា ៈ ការធ្វើសមាហរណកម្មបញ្ចូលគ្នារវាងយុទ្ធសាស្ត្រកិច្ចគាំពារសង្គម និងយុទ្ធសាស្ត្រមុខរបរ និងការងារ** ដែលជាឯកសារដ៏សំខាន់បំផុតសម្រាប់ការពិគ្រោះយោបល់ និង រៀបចំអភិវឌ្ឍន៍គោលនយោបាយរបស់យើង។

ក្នុងនាមថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខ្ញុំសូមប្រកាសគាំទ្រ និងទទួលយកនូវសមិទ្ធិផលទាំងឡាយខាងលើនេះ ហើយក្រសួងនឹងបន្តសហការជាមួយអង្គការ ILO បន្ថែមទៀត ដើម្បីឱ្យសម្រេចបាននូវគោលដៅ គឺការរៀបចំឱ្យមានគោលនយោបាយមុខរបរ និងការងារ និងកិច្ចគាំពារសង្គមក្នុងឆ្នាំខាងមុខនេះ។

សូមប្រសិទ្ធិពរ ជូនឯកឧត្តម លោកជំទាវ លោក លោកស្រី សូមជួប នូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លាងឃ្លៀតឡើយ។

សូមប្រកាសបិទដំណើរការសិក្ខាសាលាពិគ្រោះយោបល់ចាប់ពីពេលនេះតទៅ។

សូមអរគុណ!